# លក្ខន្តិកៈ

# សមាគមសង្គហៈមិត្ត បុគ្គលិក មន្ត្រីរាជការ នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

ក្រុមប្រឹក្សាភិបាល នៃ ស.ស.ប.ស.ហ.វ

គណៈកម្មការប្រតិបត្តិ

២០១៦

# លក្ខន្តិកៈ

# សមាគមសង្គហៈមិត្ត បុគ្គលិក មន្ត្រីរាជការ
# នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

ក្រុមប្រឹក្សាភិបាល នៃ ស.ស.ប.ស.ហ.វ

គណៈកម្មការប្រតិបត្តិ

២០១៦

# លក្ខន្តិកៈ
# សមាគមសង្គហៈមិត្ត បុគ្គលិក មន្ត្រីរាជការ
# នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

## ជំពូកទី១
## គោលបំណងនៃសមាគម

**ប្រការ១.-**

សមាគមសង្គហៈមិត្ត បុគ្គលិក មន្ត្រីរាជការ នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ហៅកាត់ថា "**ស.ស.ប.ស.ហ.ទ**" ត្រូវបានបង្កើតឡើងដោយមន្ត្រីរាជការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដែលមានគោលបំណងដូចតទៅ÷

- ផ្តល់ការឧបត្ថម្ភគ្នាទៅវិញទៅមក រវាងសមាជិកសមាគមទាំងអស់ដែលជាបុគ្គលិក មន្ត្រីរាជការ នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- ពង្រឹងចំណងមិត្តភាពនិងសាមគ្គីភាពរវាងបុគ្គលិក មន្ត្រីរាជការ នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ឱ្យកាន់តែរីកចម្រើន និងរឹងមាំឡើង

- ជួយឧបត្ថម្ភផ្នែកហិរញ្ញវត្ថុដល់បុគ្គលិក មន្ត្រីរាជការក្រសួង ដូចមានចែងក្នុងជំពូកទី៥ នៃលក្ខន្តិកៈសមាគម។

និមិត្តសញ្ញា អង្គការលេខ និងទីស្នាក់ការសមាគម មានកំណត់នៅក្នុងឧបសម្ព័ន្ធនៃលក្ខន្តិកៈនេះ។

## ជំពូកទី២

## សមាជិកភាព

### ប្រការ២._

សមាគមសង្គហៈមិត្ត បុគ្គលិក មន្ត្រីរាជការនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុមានសមាជិក បួន ប្រភេទ÷

**ក.** ស្ថាបនិកកិត្តិយស

**ខ.** សមាជិកកិត្តិយស

**គ.** សមាជិកទ្រទ្រង់

**ឃ.** សកម្មិកៈសមាជិក ឬសមាជិកសកម្ម។

### ប្រការ៣ ថ្មី._

ស្ថាបនិកកិត្តិយស នឹងត្រូវផ្តល់ជូនដល់ឥស្សរជន ដែលបានផ្តួចផ្តើមគំនិតបង្កើតសមាគមសង្គហៈមិត្ត តាមការអនុម័តរបស់ក្រុមប្រឹក្សាភិបាល។

សមាជិកកិត្តិយស នឹងត្រូវផ្តល់ជូនដល់ថ្នាក់ដឹកនាំ ឬអតីតថ្នាក់ដឹកនាំ នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ឬឥស្សរជនមួយចំនួនផ្សេងទៀត តាមការអនុម័តរបស់ក្រុមប្រឹក្សាភិបាល។

សមាជិកទ្រទ្រង់ ជាសមាជិកដែលបានជួយឧបត្ថម្ភជាវិភាគទានដល់សមាគមចាប់ពី ១០០.០០០ (ដប់ម៉ឺន) រៀល សម្រាប់គាំទ្រសមាគមក្នុងរយៈពេលមួយឆ្នាំ និងមិនទទួលផលប្រយោជន៍ពីសមាគមដូចសកម្មិកៈសមាជិកឡើយ។

ក្រុមប្រឹក្សាភិបាល ពិនិត្យនិងសម្រេចទទួលស្គាល់សមាជិកទ្រទ្រង់សម្រាប់រយៈពេលមួយឆ្នាំ។

## ប្រការ៤.–

សកម្មិកៈសមាជិក សំដៅដល់បុគ្គលិក មន្ត្រីរាជការនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដែលបានដាក់ពាក្យសុំចូលជាសមាជិកសមាគម ហើយត្រូវបានក្រុមប្រឹក្សាភិបាលទទួលស្គាល់។

## ប្រការ៥.–

បុគ្គលិក មន្ត្រីរាជការ នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដែលមានបំណងចូលជាសកម្មិកៈសមាជិក ត្រូវផ្តល់ជូនក្រុមប្រឹក្សាភិបាលនូវ÷

- ពាក្យសុំចូលជាសមាជិកសមាគមមួយច្បាប់
- បង់សិទ្ធិចូលជាសមាជិកចំនួន ៥.០០០ (ប្រាំពាន់) រៀល

- លិខិតបណ្ដាំមួយច្បាប់
- រូបថតចំនួន ០៣ សន្លឹក។

សកម្មិកៈសមាជិក នឹងទទួលបានប័ណ្ណសមាជិក និងលក្ខន្តិកៈចំនួនមួយច្បាប់។

**ប្រការ៦.-**

សកម្មិកៈសមាជិក ត្រូវបង់វិភាគទានប្រចាំខែចំនួន ៣.០០០ (បីពាន់) រៀល ជូនដល់សមាគម។

បែបបទនៃការបង់វិភាគទាន ត្រូវកំណត់ដោយក្រុមប្រឹក្សាភិបាល ដែលអាចកំណត់ឱ្យបង់ប្រចាំខែ ត្រីមាស ឆមាស ឬឆ្នាំ។

**ប្រការ៧.-**

សមាជិកភាពនៃសមាគម ត្រូវបាត់បង់ដោយមូលហេតុណាមួយដូចខាងក្រោម÷

**ក.** សមាជិកបានដាក់ពាក្យលាលែងជាលាយលក្ខណ៍អក្សរ និងមានចុះហត្ថលេខាជូនទៅក្រុមប្រឹក្សាភិបាល។

**ខ.** សមាជិកភាពត្រូវបានបញ្ចប់ដោយក្រុមប្រឹក្សាភិបាលដោយហេតុសាមីជនបំពេញសកម្មភាពផ្ទុយនឹងលក្ខន្តិកៈសមាគម ឬប៉ះពាល់ដល់ផលប្រយោជន៍ និងកិត្តិនាមសមាគម។

គ. ការខកខានបង់វិភាគទានប្រចាំខែជាប់ៗគ្នា ឬវិភាគទានពិសេស បន្ទាប់ពីការជូនដំណឹងចំនួនពីរលើក។

ឃ. ការផ្ទេរក្របខ័ណ្ឌចេញពីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ សម្រាប់សកម្មិកៈសមាជិក។

ង. មរណភាព។

**ប្រការ៨.-**

សមាជិកដែលបាត់បង់សមាជិកភាពតាមប្រការ ៧.ក ៧.ខ ៧.គ និង ៧.ឃ ខាងលើ មិនអាចទាមទារសំណងប្រាក់ដែលបានបង់ ឬទទួលផលប្រយោជន៍ណាមួយពីសមាគមឡើយ។

សមាជិកដែលបាត់បង់សមាជិកភាព ដូចមានចែងក្នុងប្រការ ៧.ក ៧.ខ និង៧.គ អាចចូលជាសមាជិកវិញបាន ដោយដាក់ពាក្យសុំជាថ្មីមកក្រុមប្រឹក្សាភិបាល។

សមាជិកដែលបាត់បង់សមាជិកភាព ដូចមានចែងក្នុងប្រការ ៧.ឃ មិនអាចចូលជាសមាជិកវិញបានឡើយ ប៉ុន្តែអាចរក្សាឋានៈជាសមាជិកកិត្តិយស ឬសមាជិកទ្រទ្រង់ ស្របតាមខ្លឹមសារនៃលក្ខន្តិកៈនេះ។

**ប្រការ៩.-**

សមាជិកដែលត្រូវផ្លាស់ប្តូរការងារពីអង្គភាពមួយ ទៅអង្គភាពមួយ ឬពីខេត្តមួយ ទៅខេត្តមួយ ស្ថិតនៅក្នុងក្របខ័ណ្ឌការងារនៃក្រសួង-

សេដ្ឋកិច្ចនិងហិរញ្ញវត្ថុ នៅរក្សាសមាជិកភាពក្នុងសមាគមដដែល ដោយត្រូវផ្តល់ព័ត៌មានមកគណៈកម្មការប្រតិបត្តិ។

សមាជិកដែលចូលនិវត្តន៍ ឬបានលាឈប់ពីការងាររដ្ឋនៅក្នុងក្រសួង នឹងនៅតែជាសមាជិកសមាគម ប្រសិនបើសាមីខ្លួនបន្តបង់វិភាគទានជូនសមាគម។

## ជំពូកទី៣
## ការគ្រប់គ្រង

### ប្រការ១០ ទី.-

សមាគមត្រូវដឹកនាំ និងគ្រប់គ្រងដោយក្រុមប្រឹក្សាភិបាលសមាគមសង្គហៈមិត្ត បុគ្គលិក មន្ត្រីរាជការនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ហៅកាត់ "ក្រុមប្រឹក្សាភិបាល" ដែលមានប្រធានមួយរូប អមដោយអនុប្រធានមួយចំនួន តាមការចាំបាច់ និងសមាជិកដែលជាតំណាងបុគ្គលិក មន្ត្រីរាជការ នៅតាមអគ្គលេខាធិការដ្ឋាន អគ្គនាយកដ្ឋាន អគ្គាធិការដ្ឋាន និងអង្គភាពថ្នាក់កណ្តាល ក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

ប្រធានក្រុមប្រឹក្សាភិបាលបំពេញមុខងារជាប្រធានសមាគមដើម្បីដឹកនាំ គ្រប់គ្រង និងតំណាងសមាគម។

សេដ្ឋកិច្ចនិងហិរញ្ញវត្ថុ នៅរក្សាសមាជិកភាពក្នុងសមាគមដដែល ដោយត្រូវផ្តល់ព័ត៌មានមកគណៈកម្មការប្រតិបត្តិ។

សមាជិកដែលចូលនិវត្តន៍ ឬបានលាឈប់ពីការងាររដ្ឋនៅក្នុងក្រសួង នឹងនៅតែជាសមាជិកសមាគម ប្រសិនបើសាមីខ្លួនបន្តបង់វិភាគទានជូនសមាគម។

## ជំពូកទី៣

## ការគ្រប់គ្រង

### ប្រការ១០ ថ្មី.-

សមាគមត្រូវដឹកនាំ និងគ្រប់គ្រងដោយក្រុមប្រឹក្សាភិបាលសមាគមសង្គហៈមិត្ត បុគ្គលិក មន្ត្រីរាជការនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ហៅកាត់ "ក្រុមប្រឹក្សាភិបាល" ដែលមានប្រធានមួយរូប អមដោយអនុប្រធានមួយចំនួន តាមការចាំបាច់ និងសមាជិកដែលជាតំណាងបុគ្គលិក មន្ត្រីរាជការ នៅតាមអគ្គលេខាធិការដ្ឋាន អគ្គនាយកដ្ឋាន អគ្គាធិការដ្ឋាន និងអង្គភាពថ្នាក់កណ្តាល ក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

ប្រធានក្រុមប្រឹក្សាភិបាលបំពេញមុខងារជាប្រធានសមាគមដើម្បីដឹកនាំ គ្រប់គ្រង និងតំណាងសមាគម។

បុគ្គលិក មន្ត្រីរាជការ ជាសមាជិករបស់សមាគមនៅតាមអគ្គលេខាធិការដ្ឋាន អគ្គនាយកដ្ឋាន អគ្គាធិការដ្ឋាន និងអង្គភាពថ្នាក់កណ្តាល ក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវជ្រើសរើសតំណាងរបស់ខ្លួន ដើម្បីបំពេញមុខងារជាសមាជិកក្រុមប្រឹក្សាភិបាល។

ក្រុមប្រឹក្សាភិបាលមានអាណត្តិ ៥ (ប្រាំ) ឆ្នាំ។ ដោយឡែក ចំពោះអាណត្តិទី២ ក្រុមប្រឹក្សាភិបាលមានអាណត្តិ ៤ (បួន) ឆ្នាំ។ សមាជិកក្រុមប្រឹក្សាភិបាល ត្រូវធ្វើការបោះឆ្នោតជ្រើសរើសប្រធាន និងអនុប្រធានសម្រាប់អាណត្តិនីមួយៗ ដែលត្រូវរៀបចំរួមគ្នាតែមួយលើក។

ក្រុមប្រឹក្សាភិបាល អាចពិនិត្យ និងស្នើសុំថ្នាក់ដឹកនាំក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ធ្វើជាប្រធានកិត្តិយស ដើម្បីជួយណែនាំតម្រង់ទិសការងារ ព្រមទាំងផ្តល់ការឧបត្ថម្ភគាំទ្រ និងកៀរគរជំនួយឧបត្ថម្ភ។

ដើម្បីជួយសម្រួលការបង្កើតសមាគម នៅក្នុងអាណត្តិទី១ ក្រុមប្រឹក្សាភិបាលសមាគម នឹងត្រូវរៀបចំដោយផ្អែកតាមគោលការណ៍ចាត់តាំង និងការស្ម័គ្រចិត្ត ដែលរួមមានសមាសភាព ដូចខាងក្រោម÷

- ថ្នាក់ដឹកនាំ ឬឥស្សរជននៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ មួយរូប ដែលចាត់តាំងដោយរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ជាប្រធាន
- តំណាងអគ្គលេខាធិការ/អគ្គនាយកដ្ឋាន/នាយកដ្ឋានបុគ្គលិក អនុប្រធាន

- តំណាងនាយកដ្ឋាន-អង្គភាព/អគ្គាធិការដ្ឋាន/វិទ្យាស្ថាន សមាជិក។

ក្រុមប្រឹក្សាភិបាលនៅក្នុងអាណត្តិនីមួយៗ នឹងត្រូវបញ្ចប់ភារកិច្ច នៅពេលក្រុមប្រឹក្សាភិបាលថ្មី ចូលកាន់តំណែង។

## ប្រការ១១ ថ្មី._

ក្រុមប្រឹក្សាភិបាល មានភារកិច្ចដូចខាងក្រោម÷

- គ្រប់គ្រង និងកំណត់អំពីរបៀបនៃការចាត់ចែងសមាគម ប្រកបដោយប្រសិទ្ធភាព និងតម្លាភាពដើម្បីជាប្រយោជន៍ ដល់សមាជិកសមាគមទាំងមូល
- រៀបចំគោលនយោបាយនិងយុទ្ធសាស្ត្រអំពីការគ្រប់គ្រងនិង ចាត់ចែងកិច្ចការសមាគម
- ជំរុញ និងលើកកម្ពស់ស្មារតីនៃការជួយឧបត្ថម្ភគាំទ្រគ្នារវាង បុគ្គលិក មន្ត្រីរាជការ នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- ជំរុញឱ្យគ្រប់ថ្នាក់ដឹកនាំ និងបុគ្គលិក មន្ត្រីរាជការនៃអគ្គ-លេខាធិការដ្ឋាន អគ្គនាយកដ្ឋាន អគ្គាធិការដ្ឋាន និងអង្គភាព ក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ជួយឧបត្ថម្ភគាំទ្រ និងចូលជាសមាជិកសមាគម ព្រមទាំងស្វះស្វែង និងអំពាវនាវ រកការឧបត្ថម្ភគាំទ្រទាំងផ្នែកស្មារតី និងហិរញ្ញវត្ថុពីប្រភព ខាងក្រៅ

- សម្រេចអំពីសមាជិកភាព និងកំណត់ប្រាក់វិភាគទានធម្មតា និងពិសេសរបស់សមាជិក
- កំណត់អំពីផលប្រយោជន៍ផ្សេងៗ ដែលត្រូវផ្តល់ដល់សមាជិកនៃសមាគម
- អនុម័តនិងសម្រេចកែប្រែលក្ខន្តិកៈសមាគមក្នុងករណីចាំបាច់
- អនុម័តលើគម្រោងចំណូល-ចំណាយប្រចាំឆ្នាំ និងតុល្យការគណនេយ្យ នាដំណាច់ឆ្នាំនីមួយៗ របស់សមាគម
- គ្រប់គ្រង និងចាត់ចែងទ្រព្យសម្បត្តិទាំងអស់របស់សមាគម
- កំណត់ការធ្វើសវនកម្ម លើការងារគ្រប់គ្រងហិរញ្ញវត្ថុរបស់សមាគម
- កំណត់ទីស្នាក់ការបំពេញការងាររបស់សមាគម។

## ប្រការ១២ ថ្មី.-

ក្រុមប្រឹក្សាភិបាល ត្រូវរៀបចំឱ្យមានកិច្ចប្រជុំប្រចាំឆ្នាំ និងអាចរៀបចំការប្រជុំផ្សេងទៀត តាមការចាំបាច់។ ការកោះប្រជុំវិសាមញ្ញ នៃក្រុមប្រឹក្សាភិបាល ត្រូវសម្រេចដោយប្រធានក្រុមប្រឹក្សាភិបាល។ សមាជិកក្រុមប្រឹក្សាភិបាលយ៉ាងតិចចំនួន ១/៣ (មួយភាគបី) អាចស្នើប្រធានក្រុមប្រឹក្សាភិបាលកោះប្រជុំបាន។

កិច្ចប្រជុំក្រុមប្រឹក្សាភិបាល អាចដំណើរការ និងយកជាការបានលុះត្រាតែមានកូរ៉ុមយ៉ាងតិចលើសពាក់កណ្តាល នៃចំនួនសមាជិក

ក្រុមប្រឹក្សាភិបាលទាំងមូល។ សមាជិកក្រុមប្រឹក្សាភិបាល អាចប្រគល់សិទ្ធិឱ្យអ្នកតំណាងដើម្បីចូលរួមប្រជុំ និងធ្វើការសម្រេចជំនួសខ្លួនតាមរយៈលិខិតជាលាយលក្ខណ៍អក្សរ។

ក្រុមប្រឹក្សាភិបាល សម្រេចក្នុងការអនុម័តកែប្រែលក្ខន្តិកៈសមាគម រំលាយសមាគម គម្រោងចំណូល-ចំណាយ ថវិកាដំណាច់ឆ្នាំនីមួយៗ ដោយសម្លេងភាគច្រើនដាច់ខាតនៃសមាជិកដែលវត្តមាន។ អ្នកដែលមានសិទ្ធិបោះឆ្នោតសំដៅដល់ប្រធាន អនុប្រធាន និងសមាជិកនៃក្រុមប្រឹក្សាភិបាល។ ក្នុងករណីសម្លេងបែងចែកស្មើគ្នា សម្លេងប្រធាន មានឧត្តមានុភាព។

ដោយមិនប៉ះពាល់ដល់បញ្ញត្តិដែលមានចែងក្នុងវាក្យខ័ណ្ឌខាងលើ និងបញ្ញត្តិដែលទាមទារឱ្យមានការសម្រេចផ្អែកតាមសម្លេងភាគច្រើនដាច់ខាតនៃសមាជិកក្រុមប្រឹក្សាភិបាល ប្រធានក្រុមប្រឹក្សាភិបាលក្នុងនាមជាប្រធានសមាគម ដោយមានជំនួយពីអនុប្រធាន ត្រូវបានប្រគល់សិទ្ធិក្នុងការដឹកនាំនិងគ្រប់គ្រងកិច្ចការប្រចាំថ្ងៃរបស់សមាគម ក្នុងនាមក្រុមប្រឹក្សាភិបាល និងសមាគម ដោយមានគណៈកម្មការប្រតិបត្តិ ជាសេនាធិការ។

### ប្រការ១៣._

គណៈកម្មការប្រតិបត្តិ ដឹកនាំដោយប្រធានមួយរូប ដែលមានអនុប្រធានមួយចំនួន លេខាធិការមួយរូប ហិរញ្ញិកមួយរូប និងជំនួយការ

មួយចំនួន ផ្អែកតាមការចាំបាច់។ សមាសភាពនៃគណៈកម្មការប្រតិបត្តិត្រូវតែងតាំងដោយប្រធានក្រុមប្រឹក្សាភិបាល បន្ទាប់ពីមានការពិគ្រោះយោបល់ជាមួយអនុប្រធាន។

ដោយស្ថិតនៅក្រោមការដឹកនាំ និងគ្រប់គ្រងរបស់ប្រធាន និងអនុប្រធានក្រុមប្រឹក្សាភិបាល គណៈកម្មការប្រតិបត្តិ មានភារកិច្ចដូចខាងក្រោម÷

- គាំទ្រដំណើរការក្រុមប្រឹក្សាភិបាល និងអនុវត្តចាត់ចែងការងារប្រចាំថ្ងៃផ្អែករដ្ឋបាល និងហិរញ្ញវត្ថុរបស់សមាគម
- សម្របសម្រួលនិងចាត់ចែងរៀបចំកិច្ចប្រជុំផ្សេងៗរបស់ក្រុមប្រឹក្សាភិបាល
- សម្របសម្រួល និងចាត់ចែងឱ្យមានការផ្សព្វផ្សាយទូលំទូលាយអំពីព័ត៌មានដែលពាក់ព័ន្ធនឹងសមាគមដល់បុគ្គលិក មន្ត្រីរាជការនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- ធ្វើរបាយការណ៍ប្រចាំត្រីមាស និងប្រចាំឆ្នាំ អំពីសកម្មភាពសមាគមជូនក្រុមប្រឹក្សាភិបាល
- ចាត់ចែងប្រមូលវិភាគទានស្របតាមលក្ខន្តិកៈកំណត់ និងការសម្រេចរបស់ក្រុមប្រឹក្សាភិបាល

- រក្សាតម្កល់ទុក និងធ្វើបច្ចុប្បន្នភាពបញ្ជីឈ្មោះសមាជិកសមាគម និងរៀបចំរក្សាទុករាល់ឯកសារដែលពាក់ព័ន្ធនឹងដំណើរការប្រតិបត្តិការរបស់សមាគម
- ចាត់ចែងឱ្យមានការកាន់កាប់បញ្ជីគណនេយ្យ ប្រកបដោយតម្លាភាព និងរៀបចំបើកគណនីសម្រាប់ការតម្កល់ថវិកានិងប្រតិបត្តិការហិរញ្ញវត្ថុរបស់សមាគម
- ធ្វើបញ្ជីសារពើភ័ណ្ឌ និងបច្ចុប្បន្នភាពប្រចាំឆ្នាំ ដើម្បីគ្រប់គ្រងចលនទ្រព្យ និងអចលនទ្រព្យរបស់សមាគម
- រៀបចំឱ្យមានការបើកផ្តល់ប្រាក់ឧបត្ថម្ភដល់សមាជិក ស្របតាមលក្ខន្តិកៈ និងការសម្រេចរបស់ក្រុមប្រឹក្សាភិបាល
- រៀបចំគម្រោងចំណូល-ចំណាយប្រចាំឆ្នាំ និងការអនុវត្តថវិកាប្រចាំឆ្នាំនីមួយៗ ដាក់ជូនក្រុមប្រឹក្សាភិបាលពិនិត្យនិងសម្រេច។

## ជំពូកទី៤
## ចំណូល និងចំណាយ

**ប្រការ១៤.–**

ចំណូលរបស់សមាគម បានមកពីប្រភព÷

- ប្រាក់បង់សិទ្ធិចូលសមាគមរបស់សមាជិក
- វិភាគទានប្រចាំខែនិងពិសេសរបស់សមាជិក

- អំណោយ អច្ច័យទាន ឬប្រាក់ឧបត្ថម្ភផ្សេងៗពីសប្បុរសជន
- ចំណូលពីសកម្មភាពផ្សេងៗដូចជាបុណ្យ សកម្មភាពកំសាន្ត សកម្មភាពសង្គម ដែលត្រូវបានរៀបចំជាប្រយោជន៍ដល់សមាគម
- ផលប្រយោជន៍ហិរញ្ញវត្ថុផ្សេងៗដែលកើតចេញពីការគ្រប់គ្រង និងចាត់ចែងទ្រព្យសម្បត្តិនិងថវិការបស់សមាគម។

**ប្រការ១៥.-**

ចំណាយរបស់សមាគម រួមមាន÷

- ចំណាយដែលកំណត់ដោយលក្ខន្តិកៈ
- ចំណាយសម្រាប់ប្រតិបត្តិការផ្នែកគ្រប់គ្រង និងរដ្ឋបាលរបស់សមាគម
- ចំណាយដើម្បីសកម្មភាពជាប្រយោជន៍ និងការអភិវឌ្ឍសមាគម។

## ជំពូកទី៥
## ប្រាក់ឧបត្ថម្ភដល់សមាជិក

**ប្រការ១៦.-**

ប្រាក់ឧបត្ថម្ភដល់សមាជិក រួមមានភាគទានមរណបត្ថម្ភ និងប្រាក់ឧបត្ថម្ភផ្សេងទៀតដែលមានកំណត់នៅក្នុងលក្ខន្តិកៈ។ ក្នុងករណីពិសេស ក្រុមប្រឹក្សាភិបាលអាចសម្រេចអំពីការផ្តល់ប្រាក់ឧបត្ថម្ភ តាម

សម្លេងភាគច្រើនដាច់ខាត និងផ្អែកតាមលទ្ធភាពហិរញ្ញវត្ថុជាក់ស្តែងរបស់សមាគម។

## ប្រការ១៧ ថ្មី._

ភាគទានមរណបុប្ផ ត្រូវបានកំណត់ដូចតទៅ ÷

**ក.** ៤.០០០.០០០ រៀល ចំពោះសមាជិកម្នាក់ទទួលមរណភាព។

**ខ.** ២.៥០០.០០០ រៀល ចំពោះសហព័ទ្ធស្របច្បាប់របស់សមាជិកទទួលមរណភាព។

**គ.** បើសហព័ទ្ធទាំងពីរជាសមាជិក ហើយទទួលមរណភាពក្នុងពេលជាមួយគ្នា ប្រាក់ឧបត្ថម្ភត្រូវផ្តល់ឱ្យសម្រាប់សមាជិកម្នាក់ៗ ចំនួន ៦.៥០០.០០០ រៀល គឺ÷

- ៤.០០០.០០០ រៀល ក្នុងឋានៈជាសមាជិក
- ២.៥០០.០០០ រៀល ក្នុងឋានៈជាសហព័ទ្ធសមាជិក។

**ឃ.** បើសហព័ទ្ធទាំងពីរជាសមាជិក ហើយសហព័ទ្ធណាមួយទទួលមរណភាព ប្រាក់ឧបត្ថម្ភដែលត្រូវផ្តល់ឱ្យ មានចំនួន ៦.៥០០.០០០ រៀល គឺ÷

- ៤.០០០.០០០ រៀល ក្នុងឋានៈជាសមាជិក
- ២.៥០០.០០០ រៀល ក្នុងឋានៈជាសហព័ទ្ធសមាជិក។

**ង.** ១.០០០.០០០ រៀល ចំពោះកូន ឪពុក ម្តាយបង្កើតរបស់សមាជិក ដែលទទួលមរណភាព។

**ប្រការ១៨._**

សមាជិកដែលត្រូវចាកចេញពីការងារ ដោយមូលហេតុបាត់បង់សម្បទាវិជ្ជាជីវៈ នឹងទទួលប្រាក់ឧបត្ថម្ភចំនួន ៤.០០០.០០០ រៀល។

**ប្រការ១៩._**

ក្នុងករណីមូលនិធិរបស់សមាគម មិនអាចទ្រទ្រង់ និងផ្ដល់ការឧបត្ថម្ភតាមការកំណត់នៃប្រការ១៧ និង១៨ ខាងលើ ក្រុមប្រឹក្សាភិបាល ត្រូវសម្រេចអំពីនីតិវិធីនៃការបង្កើនមូលនិធិបន្ថែម។

**ប្រការ២០ ថ្មី._**

ប្រាក់ឧបត្ថម្ភផ្នែកសង្គមផ្សេងទៀត សម្រាប់សមាជិកមានដូចជា÷

**ក.** ៤០០.០០០ រៀលសម្រាប់សមាជិកដែលសម្រាលកូន។

**ខ.** ៥០០.០០០ រៀល សម្រាប់សមាជិកដែលមានជម្ងឺធ្ងន់ធ្ងរ និងរ៉ាំរ៉ៃ។

**គ.** ៥០០.០០០ រៀល សម្រាប់សមាជិកដែលទទួលរងគ្រោះថ្នាក់រហូតដល់ពិការ។

**ឃ.** ៤.០០០.០០០ រៀល សម្រាប់ករណីភ្លើងឆេះផ្ទះអស់។

**ង.** ប្រធានក្រុមប្រឹក្សាភិបាលអាចសម្រេចការឧបត្ថម្ភក្នុងកម្រិតទឹកប្រាក់ ២.០០០.០០០ រៀលចុះ សម្រាប់សមាជិកជួបប្រទះ

នូវគ្រោះអាសន្នជាថែជន្យ ដែលមិនស្ថិតក្នុងប្រភេទឧបត្ថម្ភ កំណត់ដោយលក្ខន្តិកៈ។

ប្រធានក្រុមប្រឹក្សាភិបាល អាចចាត់តាំងក្រុមការងាររបស់គណៈកម្មការប្រតិបត្តិ ដើម្បីធ្វើការត្រួតពិនិត្យ និងវាយតម្លៃ ផ្អែកតាមករណីជាក់ស្តែងនីមួយៗ។

**ប្រការ២១.-**

តំណាងមន្ត្រីរាជការនៅតាមអង្គភាព ក្រុមគ្រួសារ ឬសាមីខ្លួន ត្រូវផ្តល់ព័ត៌មានមកគណៈកម្មការប្រតិបត្តិ អំពីមរណភាពសមាជិក មរណភាពនៃសហព័ទ្ធសមាជិក ការបញ្ឈប់សមាជិកពីការងារ មាតុភាព ស្ថានភាពជម្ងឺ ឬគ្រោះថ្នាក់ ដោយផ្តល់សំបុត្រមរណភាព ឬសេចក្តីសម្រេចបញ្ឈប់ការងារ ឬលិខិតបញ្ជាក់សុខភាព ផ្អែកតាមករណីនីមួយៗ។

ប្រធានគណៈកម្មការប្រតិបត្តិ ត្រូវរាយការណ៍ជាបន្ទាន់ដល់ប្រធានក្រុមប្រឹក្សាភិបាល ដើម្បីចាត់ចែងរៀបចំប្រាក់ឧបត្ថម្ភជូនសមាជិកសមាគម។

ក្រុមការងារផ្តល់ប្រាក់ឧបត្ថម្ភរួមមាន ប្រធានក្រុមប្រឹក្សាភិបាល ឬតំណាង តំណាងគណៈកម្មការប្រតិបត្តិ និងប្រធានអង្គភាពរបស់សមាជិក ឬតំណាង។

## ប្រការ២២.-

អ្នកដែលអាចទទួលប្រាក់ឧបត្ថម្ភពីសមាគមអាចជាសមាជិកផ្ទាល់ ឬសហព័ទ្ធនៃសមាជិក ឬសិទ្ធិវន្តដែលមានឈ្មោះក្នុងលិខិតបណ្តាំរបស់សមាជិកដែលមានតម្កល់នៅការិយាល័យ នៃគណៈកម្មការប្រតិបត្តិ។

## ប្រការ២៣ ថ្មី.-

ប្រាក់ឧបត្ថម្ភដែលបានចែងខាងលើ អាចត្រូវកំណត់ផ្សេងដោយក្រុមប្រឹក្សាភិបាល ផ្អែកតាមលទ្ធភាពហិរញ្ញវត្ថុជាក់ស្តែងរបស់សមាគម។

# ជំពូកទី៦

# ការកែប្រែលក្ខន្តិកៈ និងការរំលាយសមាគម

## ប្រការ២៤.-

លក្ខន្តិកៈសមាគមអាចត្រូវកែប្រែផ្អែកតាមភាពចាំបាច់ តាមការសម្រេចរបស់ក្រុមប្រឹក្សាភិបាល បន្ទាប់ពីមានសំណើរបស់ប្រធានក្រុមប្រឹក្សាភិបាល ឬសមាជិកក្រុមប្រឹក្សាភិបាលយ៉ាងតិចចំនួនមួយភាគបី។

សេចក្តីសម្រេចស្តីពីការកែប្រែលក្ខន្តិកៈនេះ ត្រូវអនុលោមតាមប្រការ១២ នៃលក្ខន្តិកៈនេះ។

**ប្រការ២៥.**

សមាគម អាចត្រូវរំលាយដោយសេចក្តីសម្រេចរបស់ក្រុមប្រឹក្សា-ភិបាល។ សេចក្តីសម្រេចនេះ ត្រូវអនុលោមតាម ប្រការ១២ នៃលក្ខន្តិកៈនេះ។

ខ្លឹមសារ នៃប្រការ២៤ ខាងលើ ត្រូវអនុវត្តផងដែរ ចំពោះការស្នើសុំរំលាយសមាគម។

ក្នុងករណីមានការរំលាយនេះ ទ្រព្យសម្បត្តិទាំងប៉ុន្មានរបស់សមាគម នឹងត្រូវធ្វើការផ្ទេរទៅឱ្យសមាគម ឬអង្គការ ដែលបំពេញសកម្មភាពផ្នែកមនុស្សធម៌។

លក្ខន្តិកៈសមាគមសង្គហៈមិត្ត បុគ្គលិក មន្ត្រីរាជការនៃក្រសួង-សេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវបានអនុម័ត កាលពីថ្ងៃទី០៣ ខែមីនា ឆ្នាំ ២០១១។

ប្រការ១៧ និងប្រការ២០ នៃលក្ខន្តិកៈនេះ ត្រូវបានកែប្រែដោយការសម្រេច របស់ក្រុមប្រឹក្សាភិបាល នៅថ្ងៃទី១៨ ខែកុម្ភៈ ឆ្នាំ២០១៣។

ប្រការ៣ ប្រការ១០ ប្រការ១១ ប្រការ១២ និងប្រការ២៣ ត្រូវបានកែប្រែដោយការសម្រេច របស់ក្រុមប្រឹក្សាភិបាល នៅថ្ងៃទី១៨ ខែកញ្ញា ឆ្នាំ២០១៤។

ជ.ក្រុមប្រឹក្សាភិបាល

ប្រធាន

បណ្ឌិត. អ៊ុន ពន្លឺមុនីរ័ត្ន

# ឧបសម្ព័ន្ធ នៃលក្ខន្តិកៈសមាគមសង្គហៈមិត្ត បុគ្គលិក មន្ត្រីរាជការ នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

## និមិត្តសញ្ញា

## អង្គការលេខសមាគម




## ទីស្នាក់ការ

នាយកដ្ឋានបុគ្គលិក

ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ

ទូរសព្ទ/ទូរសារ៖ ០២៣ ៤៣០ ៧៩២

គេហទំព័រ៖ www.pd.mef.gov.kh

ទំព័រហ្វេសប៊ុក៖ www.facebook.com/sangahakmitmef

លក្ខន្តិកៈសមាគមសង្គហៈមិត្ត បុគ្គលិក មន្ត្រីរាជការ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រូវបានអនុម័ត កាលពីថ្ងៃទី០៣ ខែមីនា ឆ្នាំ២០១១។ រហូតមកដល់ពេលនេះ លក្ខន្តិកៈសមាគម ត្រូវបានកែប្រែចំនួនពីរលើករួចមកហើយ ក្នុងនោះ លើកទី១ នៅក្នុងខែកុម្ភៈ ឆ្នាំ២០១៣ និងលើកទី២ នៅក្នុងខែកញ្ញា ឆ្នាំ២០១៤។

**ក្រុមប្រឹក្សាភិបាល នៃ ស.ស.ប.ស.ហ.វ**

**គណៈកម្មការប្រតិបត្តិ**